**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល**

**ក្រុមលទ្ធកម្ម**

លេខ : ០៤៣/១៨...... កល.កសក

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការងារជួសជុល និងរៀបចំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាលដំណាក់កាលទី៣

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការធ្វើការងារ ជួសជុល និងរៀបចំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាលដំណាក់កាលទី៣ ។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន ឬសហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅក្រុមលទ្ធកម្មមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល ដែលមានអាសយដ្ឋានផ្លូវជាតិលេខ២១A កែងផ្លូវ ២០៨ (តាខ្មៅ) ខេត្តកណ្តាល ចាប់ពីថ្ងៃទី២៦... ខែមីនា... ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០២៣ ៩៨៣ ២៩៣ ) និង Website: www.pda-kandal.com ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនក្រុមលទ្ធកម្មមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលយ៉ាងយូរបំផុតត្រឹម ថ្ងៃទី២៤....ខែមេសា.. ឆ្នាំ២០១៨ វេលា ម៉ោង..០៩:០០........ ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្មមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលតាមអាសយដ្ឋានខាងលើវេលាម៉ោង០៩:០០.....ថ្ងៃទី ២៤..ខែមេសា.. ឆ្នាំ២០១៨។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមសូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្មមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្តាលដើម្បីទិញឯកសារ និង សាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ..........ខែ..ចេត្រ..ឆ្នាំ......ស័ក ព.ស២៥៦១..

ធ្វើនៅកណ្តាល ថ្ងៃទី២០......ខែ.មីនា....ឆ្នាំ២០១៨

**ប្រធានមន្ទីរ និងជាប្រធានក្រុមលទ្ធកម្ម**

**ប៊ុនធួន-ស៊ីមូណា**

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ